ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងរដ្ឋប្បវេណី
លេខ:១៣២/២៩.៣.២០១២

# តាមនាមប្រជារាស្ត្រខ្មែរ

សាលដីកា
លេខ:១៥ក្រIV(ច)/២៤.៧.២០១២

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២៤.៧.២០១២

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ជាចៅក្រមប្រឹក្សា
លោក ជាចៅក្រមប្រឹក្សា

ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted] នោម ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ប្រពន្ធឈ្មោះ [redacted] ឃឹម មានកូន០៥នាក់។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

១-ចុងចម្លើយឈ្មោះ [redacted] ទី ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិស្នួលមាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ ប្ដីឈ្មោះ [redacted] យ៉ីវ មានកូន០៤នាក់ ។

២-ចុងចម្លើយឈ្មោះ [redacted] ធុន ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិកោះស្វាយ ឃុំខ្នារ ទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ ប្ដីឈ្មោះ [redacted] ធូក មានកូន០៤នាក់ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

<u>កម្មវត្ថុបណ្ដឹង:</u> ដើមចោទប្ដឹងសុំសាលក្រម:

-បញ្ឈប់ការជួលដីស្រែទំហំ៦ហិកតាពីចុងចម្លើយ ។

-បង្គាប់ឱ្យចុងចម្លើយប្រគល់ដីស្រែទំហំ៦ហិកតា ។

២៤៣



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

កាលពីអំឡុងឆ្នាំ២០០៣ ចុងចម្លើយឈ្មោះ [redacted] ធូក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យីវ ប្រពន្ធឈ្មោះ [redacted] ទី ដែលជាក្រុមគ្រួសារឪពុក-ម្តាយនិងកូន បានខ្ចីប្រាក់របស់ឈ្មោះ [redacted] ឆោម ជាដើមចោទដើម្បីយកទៅជួញដូរសត្វគោ-ក្របីទៅវៀតណាម ដោយរកស៊ីខាតបង់មិនអាចរកប្រាក់សងបំណុលទៅឱ្យដើមចោទវិញ។ នៅថ្ងៃទី០១ ខែឧសភា ២០០៣ ចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី បានលក់ដីស្រែទំហំ ២០.០០០ម$^2$(ពីរម៉ឺនម៉ែត្រការ៉េ)តម្លៃ៤.០០០.០០០(បួនលានរៀល) មកឱ្យដើមចោទឈ្មោះ [redacted] ឆោម(មានឯកសារបញ្ជាក់) និង ក្រោយមកទៀតនៅក្នុងថ្ងៃទី០៦.០២.២០០៦ ចុងចម្លើយឈ្មោះ [redacted] ធូក និងប្រពន្ធឈ្មោះ [redacted] ធុន ត្រូវជាឪពុកម្តាយបង្កើតរបស់ចុងចម្លើយឈ្មោះ [redacted] យីវ បានលក់ដីស្រែទំហំ៤០.០០០ម$^2$(បួនម៉ឺនម៉ែត្រការ៉េ) មកឱ្យដើមចោទឈ្មោះ [redacted] ឆោម ទៀត(មានឯកសារបញ្ជាក់) ដើម្បីកាត់ប្រាក់ជំពាក់ ។ ក្រោយពីទិញរួច ដើមចោទបានជួលដីស្រែទាំងពីរកន្លែងនោះទៅឱ្យចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី ធ្វើស្រែទាំង៦(ប្រាំមួយហិកតា) ដោយយកឈ្នួលក្នុងមួយហិកតាជាស្រូវទំងន់៤០០គីឡូក្រាម(មានឯកសារបញ្ជាក់) ។ ចុងចម្លើយឈ្មោះ [redacted] យីវ និងប្រពន្ធឈ្មោះ [redacted] ទី បានឱ្យឈ្នួលស្រែជារៀងរាល់ឆ្នាំ លើកលែងតែនៅក្នុងឆ្នាំ២០១០ ចុងចម្លើយនៅខ្វះឈ្នួលស្រែចំនួន២.០០០.០០០៛(ពីរលានរៀល) បន្ទាប់មកថាឈប់ឱ្យឈ្នួលទៅឆ្នាំបន្តទៀតមកឱ្យដើមចោទ ដោយអះអាងថាមិនប្រគល់ដីស្រែនោះមកឱ្យដើមចោទទេ ព្រោះខ្លួនមិនបានលក់ឱ្យដើមចោទ ។ ក្រោយពីលក់ដីរួចចុងចម្លើយនៅជំពាក់បំណុលដើមចោទ ដែលបានខ្ចីមួយចំនួនទៀត ដើមចោទទាមទារឱ្យចុងចម្លើយសងប្រាក់ ជំពាក់សរុបទាំងប្រាក់ខ្ចី និង ប្រាក់ឈ្នួលស្រែចំនួន១៧.៥០០.០០០៛ (ដប់ប្រាំពីរលានប្រាំរយពាន់រៀល) ដែលចុងចម្លើយមិនទាន់បានសង ។

## ការអះអាងរបស់គូភាគី

-ដើមចោទឈ្មោះ [redacted] ឆោម ធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីដំបូងធ្លាប់ឱ្យគាត់ខ្ចីលុយពីឆ្នាំ២០០៣ ចុងក្រោយនៅសល់លុយខ្ចី១៨លាន៥០ម៉ឺនរៀល ។ ឈ្មោះ [redacted] យីវ, [redacted] ទី ទាំងថ្លៃស្រែ ទាំងលុយជំពាក់១៧លាន ៥០ម៉ឺនរៀល ។ ការខ្ចីមានច្រើនដង សរុបទាំងអស់១៧លាន៥០ម៉ឺនរៀល ។ ខ្លួនមិនដែលធ្វើកិច្ចសន្យាទេ លិខិតលក់ផ្តាច់នៅឆ្នាំ២០០៣ ។ លិខិតលក់ផ្តាច់ខ្លួនជាអ្នកសរសេរ ហើយអ្នកលក់យកស៊ីញ៉េភូមិ-ឃុំខ្លួនឯងទើបខ្លួនឱ្យលុយ ។

-មេធាវី [redacted] សន្និដ្ឋានថា៖ អង្គហេតុដំបូង គឺកើតឡើងពីការខ្ចីប្រាក់ដោយដាក់ដីស្រែចំនួនបួនលានរៀល ដោយយកការប្រាក់ជាផលស្រូវ ។ ហើយខ្ចីលើកទី២ចំនួន១៥លានរៀល ដោយគិតជាផលស្រូវដូចគ្នា ។ ករណីនេះមិនមានជាការទិញលក់ទេ គាត់បានធ្វើលិខិតលក់ផ្តាច់ កូនក្តីខ្លួនបានតវ៉ា រឿងនេះជារឿងខ្ចីលុយដាក់

បញ្ចាំស្រែមិនមានជាការទិញលក់ទេ ដល់ឆ្នាំកូនក្តីខ្លួនយកលុយទៅលោះ គាត់មិនព្រមទើបមានរឿងមកដល់តុលាការ ។ កូនក្តីខ្លួនសុខចិត្តសងប្រាក់ចំនួន២៥លានរៀល និង សុំទាមទារយកដីស្រែវិញ ។

-មេធាវី [redacted] សន្និដ្ឋានថា: កូនក្តីម្ខាងទៀតពិតជាបានលក់ដីឱ្យកូនក្តីខ្លួនមែន សុំឱ្យតុលាការតម្កល់សាលក្រមរបស់តុលាការខេត្តពោធិ៍សាត់ ទុកជាបានការដដែល ។

-ចុងចម្លើយឈ្មោះ [redacted] ទី (អវត្តមាន)

-ចុងចម្លើយឈ្មោះ [redacted] ឆុន (អវត្តមាន)

## សំអាងហេតុ

## យល់ឃើញថា

១-សេចក្តីថ្លែងពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] ធួក និងឈ្មោះ [redacted] ទី ចុះថ្ងៃទី២៨.១២.២០១១ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ:១៦(ជ) ចុះថ្ងៃទី០៦.១២.២០១១ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចនៃសាលក្រម ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-នាពេលទាញហេតុផលផ្ទាល់មាត់ ដើមចោទឈ្មោះ [redacted] ឆោម បានថ្លែងការណ៍ទទួលស្គាល់ថា មុនដំបូងភាគីចុងចម្លើយឈ្មោះ [redacted] ទី និងប្តីឈ្មោះ [redacted] យឺវ និងចុងចម្លើយឈ្មោះ [redacted] ធួក ពិតជាបានខ្ចីប្រាក់ខ្លួនយកទៅរកស៊ីប្រាកដមែន ក្រោយមកគ្មានប្រាក់សងវិញ ទើបលក់ដីដើម្បីកាត់បំណុលជំពាក់ ដោយភាគីចុងចម្លើយជាអ្នករត់ការចុះហត្ថលេខាមេភូមិ ឃុំដោយខ្លួនឯង ។ ការថ្លែងការណ៍នេះស្របគ្នានឹងចម្លើយដែលទទួលស្គាល់ការជំពាក់ប្រាក់ពីឈ្មោះ [redacted] ឆោម តែបដិសេធថាមិនបានលក់ដីនោះទេ គឺជាការបញ្ចាំធានាប៉ុណ្ណោះ ។

៣-ការថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] ឆោម ថា ជាការលក់ដីស្រែផ្តាច់មកឱ្យខ្លួនរបស់ចុងចម្លើយដើម្បីកាត់កងបំណុលជំពាក់នោះ អាចឱ្យតុលាការជឿបាន ពីព្រោះមានភស្តុតាងជាឯកសារកិច្ចសន្យាលក់ផ្តាច់ដីចុះថ្ងៃ០១.០៥.២០០៣ រវាងឈ្មោះ [redacted] យឺវ និងប្រពន្ធ [redacted] ទី ចំនួន២ហិកតា ទៅឱ្យឈ្មោះ [redacted] ឆោម មានមេភូមិដឹងឮ និងសាក្សីដឹងឮ ។ កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃ០៦.០២.២០០៦ រវាងឈ្មោះ [redacted] ធួក និងប្រពន្ធ [redacted] ឆុន ចំនួន ៤ហិកតា ទៅឱ្យឈ្មោះ [redacted] ឆោម មានមេភូមិសាក្សី និងមេឃុំដឹងឮ ។ កិច្ចសន្យាដូរដីស្រែចំនួន៦ហិកតា ចុះថ្ងៃ ០៦.៦.២០០៧ រវាងឈ្មោះ [redacted] យឺវ និងប្រពន្ធ [redacted] ទី ពីឈ្មោះ [redacted] ឆោម មានសាក្សីនិងមេភូមិដឹងឮ ។ តាមភស្តុតាងជាឯកសារខាងលើបង្ហាញថា ចុងចម្លើយទាំងអស់ពិតជាបានលក់ដីស្រែសរុបចំនួន៦ហិកតា ទៅឱ្យដើមចោទ [redacted] ឆោម និងសុំដូរដីស្រែនោះពីឈ្មោះ [redacted] ឆោម វិញប្រាកដមែន មិនមែនជាការបញ្ចាំដីស្រែធានាបំណុលទេ ។

២៤៩



២៤៤

រីឯការថ្លែងការណ៍របស់ចុងចម្លើយទាំងអស់ ថាមិនមែនជាការលក់ផ្តាច់ដីស្រែទាំង៦ហិកតា ទៅឱ្យដើមចោទ [redacted] ឆោម ទេ គឺគ្រាន់តែជាការដាក់បញ្ចាំដីស្រែធានាបំណុល នោះមិនអាចឱ្យតុលាការជឿបានទេ ពីព្រោះថ្លែងការតែមាត់ គ្មានភស្តុតាងជាឯកសារបញ្ជាក់ថាជាការបញ្ចាំដីស្រែទេ ។ ចំពោះលិខិតបញ្ជាក់ពីការប្រគល់សម្បត្តិធានា ដែលចុងចម្លើយបានដាក់នាពេលទាញហេតុផលផ្ទាល់មាត់ រវាងឈ្មោះ [redacted] ឆោម និង [redacted] យ៉ីវ និង [redacted] ទី ឃើញមានបញ្ជាក់ថាជំពាក់ប្រាក់ចំនួនសរុបទាំងដើមទាំងចុង ចំនួន១២៨៩ម៉ឺនរៀល ប៉ុន្តែលិខិតនេះឃើញថាមានកោសលុបឆ្នាំ ដែលមិនអាចឱ្យតុលាការយកមកធ្វើជាមូលដ្ឋានពិចារណាបានទេ ព្រោះជាលិខិតមានវិការៈដោយសារកោសលុបកែប្រែកាលបរិច្ឆេទឆ្នាំ ។

៤-ក្រៅពីការយល់ឃើញខាងលើ ក្រុមប្រឹក្សាឯកភាពទាំងស្រុងលើសំអាងហេតុ ដែលមានក្នុងសាលក្រមលេខៈ១៦(ផ) ចុះថ្ងៃទី០៦.១២.២០១១ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដោយមិនចាំបាច់លើកមកសំអាងជាថ្មីទេ។

៥-សាលក្រមរដ្ឋប្បវេណីលេខៈ១៦(ផ) ចុះថ្ងៃទី០៦.១២.២០១១ របស់សាលាដំបូងខេត្តពោធិសាត់ បានសម្រេចមកមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ច្រានចោលពាក្យបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ ហាក់ ធួក និង វ៉ុន ទី ចុះថ្ងៃទី២៨.១២.២០១១ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខៈ១៦(ផ) ចុះថ្ងៃទី០៦.១២.២០១១ របស់សាលាដំបូងខេត្តពោធិ៍សាត់ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] ធួក និង [redacted] ទី ។

-សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៤.០៧.២០១២ ។ បើកសិទ្ធិប្តឹងសាទុក្ខ ក្នុងរយៈពេល១ខែ គិតពីថ្ងៃទទួលការបញ្ជូនសាលដីកានេះ ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេខា [redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី..២០...ខែសីហា.ឆ្នាំ២០១២
ក្រឡាបញ្ជី

[redacted]

២៤៦



246

Scanned with CamScanner